# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ១-ព្រះរាជក្រម

០៧-០២-២០០២ -ព្រះរាជក្រមនស/រកម/០២០២/០០៧ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋក្រូអាស្យា និងការការពារទៅវិញទៅមកនូវការវិនិយោគ ៤២២

០៧-០២-២០០២ -ព្រះរាជក្រមនស/រកម/០២០២/០០៧ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋគុយបា និងការការពារទៅវិញទៅមកនូវការវិនិយោគ ៤២៤

### ២-ព្រះរាជក្រឹត្យ

០២-០២-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០២០២/០២៧ ស្តីពីការតែងតាំងឯកឧត្តម **ចម ប្រសិទ្ធ** ជា **ឧកញ៉ា** ៤២៦

១៥-០២-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០២០២/០៣៧ ស្តីពីការបំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** ជូនមន្ត្រីជាន់ខ្ពស់ ចំនួន១០ រូប នៃខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ៤២៧

១៥-០២-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០២០២/០៣៨ ប្រោសព្រះរាជទាន ចំពោះលោកឧកញ៉ា **ឆាន ខៀន** នូវគ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** ៤២៩

១៦-០២-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០២០២/០៣៩ ស្តីពីការតែងតាំងឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ជាថ្មីម្តងទៀត ៤៣០

១៦-០២-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០២០២/០៤០ ស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ហៅកាត់ថា (គ.ជ.គ.ម ឬ NCDM) ៤៣១

១៧-០២-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០២០២/០៤១ ស្តីពីការតែងតាំងលោក **ណាត ម៉ុនឡឿន** ជាអគ្គលេខាធិការ នៃគណៈកម្មាធិការជាតិអប់រំសំរាប់ទាំងអស់គ្នា ៤៣៤

១៧-០២-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០២០២/០៤២ ស្តីពីការតែងតាំងឯកឧត្តម **មុត ខៀវ** ជា **ឧកញ៉ា** ៤៣៥

# II-រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ


២១-០២-២០០២ -អនុក្រឹត្យលេខ ១៣ អនក្រ.បក ស្តីពីការតំលើងមជ្ឈមណ្ឌលហ្វឹកហ្វឺនកីឡា ទៅជាមជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា ៤៣៦

២១-០២-២០០២ -អនុក្រឹត្យលេខ ១៤ អនក្រ.បក ស្តីពីការតំលើងការិយាល័យអប់រំកាយ និងកីឡាសិស្ស-និស្សិត ទៅជានាយកដ្ឋានអប់រំកាយ និងកីឡា សិស្ស-និស្សិត ៤៣៨

២១-០២-២០០២ -អនុក្រឹត្យលេខ ១៥ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៤៤០

១៩-០២-២០០២ -អនុក្រឹត្យលេខ ៨៨ អនក្រ.តត ស្តីពីការបញ្ចប់អាណត្តិបេសកកម្មរបស់មន្ត្រីការទូត ៤៤២

១៩-០២-២០០២ -អនុក្រឹត្យលេខ ៨៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៤៣

២០-០២-២០០២ -អនុក្រឹត្យលេខ ៩០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៤៤

២០-០២-២០០២ -អនុក្រឹត្យលេខ ៩១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៤៥

២១-០២-២០០២ -អនុក្រឹត្យលេខ ៩២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៤៦

២១-០២-២០០២ -អនុក្រឹត្យលេខ ៩៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៤៧

២១-០២-២០០២ -អនុក្រឹត្យលេខ ៩៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៤៩

២១-០២-២០០២ -អនុក្រឹត្យលេខ ៩៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៥១

២១-០២-២០០២ -អនុក្រឹត្យលេខ ៩៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៥២

២១-០២-២០០២ -អនុក្រឹត្យលេខ ៩៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៥៤

២១-០២-២០០២ -អនុក្រឹត្យលេខ ៩៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៥៦

២២-០២-២០០២ -អនុក្រឹត្យលេខ ៩៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៥៧


## ២-សេចក្តីសំរេច


១៨-០២-២០០២ -សេចក្តីសំរេចលេខ ១៤ សសរ.ស្តីពីការបង្កើតគណៈកម្មការចាត់ចែងការធ្វើមាតុភូមិនិវត្តន៍ពីសហរដ្ឋអាមេរិករបស់ជនជាតិកម្ពុជា ៤៥៨


# II-ការងារបណ្តាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ


១៨-០២-២០០២ -ប្រកាសអន្តរក្រសួងស្តីពីការតែងតាំងភ្នាក់ងារបើកផ្តល់សំរាប់បើកបៀវត្ស និង ប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ជូនមន្ត្រីរាជការ ៤៦០

# ព្រះរាជក្រម

នស/រកម/០២០២/០០៧

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋក្រូអាស្យា ស្តីពីការជំរុញ និងការការពារទៅវិញទៅមកនូវការវិនិយោគ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៧ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបាន អនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០២ នាសម័យ ប្រជុំពេញអង្គលើក ទី ៦ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់ស្តីពី
# ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋក្រូអាស្យាស្តីពីការជំរុញនិងការការពារទៅវិញទៅមកនូវការវិនិយោគ

មាត្រា ១.-

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋក្រូអាស្យាស្តីពីការជំរុញ និងការការពារទៅវិញទៅមកនូវការវិនិយោគដែលធ្វើនៅទីក្រុង ប៊ុយសែល នាថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០១ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០២

នស/រកម.០២០២.០០៣៥

**ព្រះមហាក្សត្រលេខា និង ព្រះរាជលញ្ចករ**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ហត្ថលេខា**

**គាត ឈន់**

លេខ: ៤១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ២០០២
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សុខ ឆាន**

# ព្រះរាជក្រម

នស/រកម/០២០២/០០៨

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋគូបា ស្តីពីការជំរុញនិងការការពារវិនិយោគ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៧ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើក ទី ៦ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់

## ស្តីពី

## ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋគុយបា ស្តីពីការជំរុញនិងការការពារវិនិយោគ

**មាត្រា ១.-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណា-ចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋគុយបា ស្តីពីការជំរុញនិងការការពារវិនិយោគ ដែលធ្វើនៅរាជធានីភ្នំពេញ នាថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០១ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០២

៣រល.០២.០២-០០៣៦

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ហត្ថលេខា**

**គាត ឈន់**

លេខ : ៤២ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ . ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាំឌី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០២០២/០២៧

**យើង**

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

**តែងតាំង**

ឯកឧត្តម ចម ប្រសិទ្ធ

ជា

**ឧកញ៉ា**

*ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០២*

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

៣រល.០២.០២.០០៣២

លេខ: ៤៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ. ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាំឌី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០២០២/០៣៧

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : បំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** ជូនមន្ត្រីជាន់ខ្ពស់ចំនួន ១០ រូប នៃខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច ការងារបំរើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :

| | | | |
|---|---|---|---|
| ១- ឯកឧត្តម ឧត្តមសេនីយ៍ទោ | **យូ** | **ស៊ុនឡុង** | ទីប្រឹក្សាសន្តិសុខសម្តេចនាយករដ្ឋមន្ត្រី |
| ២- ឯកឧត្តម | **ទ្រាក់** | **វណ្ណឌី** | នាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី |
| ៣- ឯកឧត្តម ឧត្តមសេនីយ៍ទោ | **ហ៊ុយ** | **ពិសិដ្ឋ** | ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី |
| ៤- ឯកឧត្តម ឧត្តមសេនីយ៍ទោ | **ហ៊ីង** | **ប៊ុនហៀង** | នាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី |
| ៥- ឯកឧត្តម | **ហ៊ុន** | **ស៊ីថា** | នាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី |
| ៦- ឯកឧត្តម ឧត្តមសេនីយ៍ | **លឹម** | **លាងសែ** | នាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី |
| ៧- ឯកឧត្តម ឧត្តមសេនីយ៍ទោ | **ទៅ** | **តុល** | ជំនួយការផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី |

៨- ឯកឧត្តម ឧត្តមសេនីយ៍ គីម ប៊ុនថាន នាយករងខុទ្ទកាល័យអគ្គបញ្ជាការដ្ឋាន

៩- លោកឧត្តមសេនីយ៍ត្រី ឡេង សារុន មេបញ្ជាការកងឯកភាពអង្គរក្ស

១០- លោកឧត្តមសេនីយ៍ត្រី សុខ ចារុណ្ណ មេបញ្ជាការកងឯកភាពអង្គរក្ស

**មាត្រា ២** : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ ។

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

លេខ : ៤៤ ច.ល

ដើម្បីចម្លងចែក

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០២

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ តាន់

៣៤ល.០២.៤២.០០៤៥

# ព្រះរាជក្រឹត្យ

នស/រកត/០២០២/០៣៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

លោកឧកញ៉ា ឃាន ឡឿន

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខ : ៤៥ ច.ល

ដើម្បីចម្លងចែក

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០២

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាឌី តាន

៣១ល. ០៤.០៤.០០៤៦

# ព្រះរាជក្រឹត្យ

នស/រកត/០២០២/០៣៩

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃធនាគារជាតិ នៃកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំង ឯកឧត្តម **ជា ចាន់តូ** ជា **អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា** ជាថ្មីម្តងទៀត ។

**មាត្រា ២** : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

**ព្រះហស្ថលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

លេខ : ៤៨ ច.ល

ដើម្បីចម្លងចែក

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០២

រាជធានីភ្នំពេញ . ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាវី តាន់**

៣/ស-០២.០២.០០៤៧

# ព្រះរាជក្រឹត្យ

នស/រកត/០២០២/០៤០

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** បង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ហៅកាត់ ( គ.ជ.គ.ម ឬ NCDM ) ដែលមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១- នាយករដ្ឋមន្ត្រី | ប្រធាន |
| ២- ឥស្សរជនជាន់ខ្ពស់មួយរូប | អនុប្រធានទី១ |
| ៣- រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤- រដ្ឋមន្ត្រី ក្រសួងការពារជាតិ | អនុប្រធាន |
| ៥- រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦- រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |

៧-រដ្ឋមន្ត្រី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៨-រដ្ឋមន្ត្រី ក្រសួងធនធានទឹក និងឧតុនិយម សមាជិក

៩-រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

១០-រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម សមាជិក

១១-រដ្ឋមន្ត្រី ក្រសួងសុខាភិបាល សមាជិក

១២-រដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

១៣-រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

១៤-រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា សមាជិក

១៥-តំណាង អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ សមាជិក

១៦-តំណាង ប្រធានសមាគមជាតិកាកបាទក្រហមកម្ពុជា សមាជិក

១៧-រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សមាជិក

**មាត្រា២.-** គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ជាស្ថាប័នចំណុះរាជរដ្ឋាភិបាល និងមានភារកិច្ចដូចតទៅ :

ក- ធ្វើការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន របស់រាជរដ្ឋាភិបាល ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល សហគមន៍អន្តរជាតិ និងសប្បុរសជនក្នុង ស្រុក ដើម្បីកៀរគរជំនួយសម្រាប់ឆ្លើយតប សង្គ្រោះបន្ទាន់ និងស្តារឡើងវិញ ។

ខ- ផ្តល់យោបល់ជូនរាជរដ្ឋាភិបាល ដាក់ចេញគោលការណ៍ គោលនយោបាយសំខាន់ៗ សេចក្តីប្រកាស ដើម្បីត្រៀមបង្ការ និងគ្រប់គ្រងគ្រោះមហន្តរាយ ព្រមទាំងវិធានការឆ្លើយតបសង្គ្រោះបន្ទាន់ ការធ្វើអន្តរាគមន៍ជម្លៀសប្រជាជនទៅទីសុវត្ថិភាព ។

គ- ផ្សព្វផ្សាយការងារគ្រប់គ្រងគ្រោះមហន្តរាយដល់សហគមន៍ និងពង្រឹងខ្សែបណ្តោយ ពីថ្នាក់ជាតិ ក្រសួង ស្ថាប័នពាក់ព័ន្ធ រហូតដល់ ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ ព្រមទាំងបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីបង្កើនសមត្ថភាពការងារគ្រប់គ្រងគ្រោះមហន្តរាយ ឱ្យកាន់តែរឹងមាំ និងមានប្រសិទ្ធភាព ។

ឃ- លើកសំណើជូនរាជរដ្ឋាភិបាលអំពីការត្រៀមបម្រុងនូវមូលនិធិ សម្ភារៈ ប្រេងឥន្ធនៈមធ្យោបាយ ធនធានមនុស្ស ដើម្បីត្រៀមបង្ការ និងធ្វើអន្តរាគមន៍ឆ្លើយតបសង្គ្រោះបន្ទាន់ និងស្តារ

ឡើងវិញមុនពេល ក្នុងពេល និងក្រោយពេលកើតមានគ្រោះមហន្តរាយ ដើម្បីភាពម្ចាស់ការជាមុន ។

**មាត្រា៣.-** គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មានអគ្គលេខាធិការដ្ឋានមួយ ដឹកនាំដោយអគ្គលេខាធិការមួយរូប និងអគ្គលេខាធិការរង មួយចំនួន តាមការចាំបាច់ជាជំនួយការ ។

**មាត្រា៤.-** សមាជិកគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវចូលរួមប្រជុំតាមការអញ្ជើញ របស់ប្រធាន ។

**មាត្រា៥.-** ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា៦.-** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីព្រះរាជក្រឹត្យនេះ ចាត់ទុកជានិរាករណ៍ ។

**មាត្រា៧.-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ។

**មាត្រា៨.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

លេខ : ៤៦ ច.ល

ដើម្បីចម្លងចែក

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០២*

រាជធានីភ្នំពេញ . ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ២០០២

*៣រល.០២.០២.០០៤៩*

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សាខឺ តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០២០២/០៤១

យើង

ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត ជិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី ការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងលោក **ណាត ប៊ុនរឿន** ជាអគ្គលេខាធិការ នៃគណៈកម្មាធិការជាតិអប់រំសំរាប់ទាំងអស់គ្នា មានឋានៈស្មើ អគ្គនាយក ។

**មាត្រា ២:** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

**ព្រះហស្ថលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

លេខ : ៤៧ ច.ល

*ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០២*

ចរក-០២០២-០០៤៩

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ . ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាឌី .តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០២០២/០៤២

## យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

## តែងតាំង

ឯកឧត្តម មុត ខៀវ

ជា

ឧកញ៉ា

ព្រះហស្ថលេខា និង ព្រះរាជលញ្ឆករ
**នរោត្តម សីហនុ**

លេខ : ៣៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០២
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សុខ ទីតាន់**

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០២

ពរស.០២.០៥.០០៥០

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៣.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតំលើងមជ្ឈមណ្ឌលហ្វឹកហ្វឺនកីឡា ទៅជាមជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១/អនក្រ/បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងអប់រំ យុវជន និង កីឡា
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

## សំ រេ ច

**មាត្រា ១ :**

ត្រូវបានតំលើងមជ្ឈមណ្ឌលហ្វឹកហ្វឺនកីឡា អោយទៅជា មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា ចំណុះអគ្គនាយកដ្ឋាន យុវជន និង កីឡា នៃក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ២ :**

មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា មានមុខងារ និង ភារកិច្ចដូចខាងក្រោម ÷

- ប្រមូលផ្តុំគ្រូបង្វឹក អនុរក្ស កីឡាករ កីឡាការិនី ជំរើសជាតិ គ្រប់វិញ្ញាសាមកធ្វើការបំប៉ន ហាត់ហ្វឹកហ្វឺន ដើម្បីត្រៀមលក្ខណៈចូលរួមប្រកួតលក្ខណៈអន្តរជាតិ
- សហការជាមួយគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា និង គ្រប់សហព័ន្ធកីឡាជាតិ ក្នុងការជ្រើសរើសកីឡាករ កីឡាការិនី ជំរើសជាតិ
- រៀបចំបង្កើត និង គ្រប់គ្រងមជ្ឈមណ្ឌលហ្វឹកហ្វឺនកីឡាតាមភូមិភាគ
- រៀបចំផែនការហាត់ហ្វឹកហ្វឺន និង ធ្វើការត្រួតពិនិត្យ តាមដានលទ្ធផលបច្ចេកទេសលើគ្រប់វិញ្ញាសា ។

**មាត្រា ៣ :**

មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា មានឋានៈ និង បុព្វសិទ្ធ ស្មើនាយកដ្ឋាន ដែលដឹកនាំដោយប្រធាន មួយរូប និង អនុប្រធាន មួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៤ :**

ភារកិច្ចជាក់ស្តែង និង រចនាសម្ព័ន្ធរបស់ មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៥ :**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែ កុម្ភៈ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួង ព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦ " *ដើម្បីអនុវត្ត* "
- ឯកសារ - កាលប្បវត្តិ.

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការតំលើងការិយាល័យអប់រំកាយ និង កីឡាសិស្ស-និស្សិត ទៅជានាយកដ្ឋានអប់រំកាយ និង កីឡាសិស្ស-និស្សិត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១/អនក្រ/បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងអប់រំ យុវជន និង កីឡា
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

## ស ំ រេ ច

### មាត្រា ១ :

ត្រូវបានតំលើងការិយាល័យអប់រំកាយ និង កីឡាសិស្ស-និស្សិត អោយទៅជានាយកដ្ឋានអប់រំកាយ និង កីឡាសិស្ស-និស្សិត ចំណុះអគ្គនាយកដ្ឋាន យុវជន និង កីឡា នៃក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ២ :**

នាយកដ្ឋានអប់រំកាយ និង កីឡាសិស្ស-និស្សិត មានភារកិច្ច ÷

- គ្រប់គ្រងការងារអប់រំកាយ និង កីឡា ក្នុងជួរសិស្ស-និស្សិត គ្រប់គ្រឹះស្ថានសិក្សា
- បំផុស និង អភិវឌ្ឍសកម្មភាពអប់រំកាយ និង កីឡា តាមគ្រឹះស្ថានសិក្សា ក្នុង និង ក្រៅម៉ោងសិក្សា និងជំរុញសកម្មភាពសហព័ន្ធកីឡាសិស្ស-និស្សិត ដើម្បីចូលរួមប្រកួតលើឆាកអន្តរជាតិ
- រៀបចំកម្មវិធីសិក្សាមុខវិជ្ជា អប់រំកាយ និង កីឡា ហើយបញ្ចូលមុខវិជ្ជានេះ ទៅក្នុងការប្រលងនានា
- រៀបចំការប្រកួតកីឡា សិស្ស-និស្សិត និង ធ្វើអធិការកិច្ចលើមុខវិជ្ជា អប់រំកាយ និង កីឡា តាមគ្រប់ភូមិសិក្សា ។

**មាត្រា ៣ :**

នាយកដ្ឋានអប់រំកាយ និង កីឡាសិស្ស-និស្សិត ដែលដឹកនាំការងារដោយ ប្រធាន មួយរូប និង អនុប្រធាន មួយចំនួនជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៤ :**

ភារកិច្ចជាក់ស្តែង និង រចនាសម្ព័ន្ធរបស់ នាយកដ្ឋានអប់រំកាយ និង កីឡា សិស្ស-និស្សិត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៥ :**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួង អប់រំ យុវជន និង កីឡា រដ្ឋមន្ត្រី ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃ រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួង ព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦ "*ដើម្បីអនុវត្ត*"
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

**********

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២, ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ , ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបែងចែកឥណទានថវិកាចំណាយតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ១.០០០ លានរៀល ( មួយពាន់លានរៀលគត់ ) ពីជំពូក ៤០ ( ចំណាយផ្សេងៗ ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច ) របស់ក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលទូទៅ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ចំណាយការពារសន្តិសុខ សុវត្ថិភាពក្នុងពេលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីជំរាបជូន**
**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការបញ្ចប់អាណត្តិបេសកកម្មរបស់មន្ត្រីការទូត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ៧៧ / អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

## សំរេច

**មាត្រា១ :** ត្រូវបានផ្លាស់ លោក អេង យេង បច្ចុប្បន្នអគ្គទីប្រឹក្សា និង លោក សោម ស៊ុនណា ទីប្រឹក្សាស្ថានទូតកម្ពុជា ប្រចាំប្រទេសអូស្ត្រាលីនិងនូវែលហ្សេឡង់ អោយមកបំរើការងារនៅក្នុងប្រទេសវិញ ដោយចប់អាណត្តិបេសកកម្ម ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

ចំលងជូន :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
